# សុន្ទរកថា

## ឯកឧត្តម វេជ្ជបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ថ្លែងក្នុងពិធីបើក សន្និបាតបូកសរុបសមិទ្ធផលការងារឆ្នាំ២០១២

## របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

សណ្ឋាគារ ណាហ្គាវើល រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមិនា ឆ្នាំ២០១៣

-សូមគោរព លោកវេជ្ជ. Pieter JM Van Maaren តំណាងអង្គការសុខភាពពិភពលោក ប្រចាំកម្ពុជា

-សូមគោរពឯកឧត្តមលោកជំទាវតំណាងអាជ្ញាធរខេត្តនិងប្រធានក្រុមការងារពិសេស លុបបំបាត់ជំងឺគ្រុនចាញ់ខេត្ត

-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី តំណាងអង្គការជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និង ម្ចាស់ជំនួយទាំងអស់ ព្រមទាំងសមាជិក សមាជិកា នៃអង្គសន្និបាតទាំងមូល ជាទីមេត្រី

ក្នុងនាមក្រសួងសុខាភិបាល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ថ្ងៃនេះខ្ញុំមានមនោសញ្ចេតនារំភើបរីករាយ ឥតឧបមា និងមានកិត្តិយសដ៏ឧត្តុងឧត្តម ដែលបានចូលរួមក្នុងពិធីបើកសន្និបាតបូកសរុបសមិទ្ធផលការងារឆ្នាំ២០១២ របស់មជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

ជំងឺគ្រុនចាញ់-គ្រុនឈាម ជំងឺប៉ារ៉ាស៊ីត និងជំងឺបង្កដោយវីរុសមួយចំនួនទៀត ដែលចំលងដោយមូស គឺជាបញ្ហាអាទិភាព ក្នុងចំណោមជំងឺឆ្លងនានាឈានមុខគេនៅក្នុងប្រទេសកម្ពុជា ដែលក្រសួងសុខាភិបាល កំពុងតែយកចិត្តទុកដាក់ក្នុងការប្រយុទ្ធ ឬលុបបំបាត់ ក្នុងនោះជំងឺខ្លះដូចជាជំងឺគ្រុនចាញ់ គ្រុនឈាម ជាជំងឺ ដែលមានមុខអាចឱ្យប្រជាជន-សហគមន៍ស្គាល់ឬ ដឹងឮជាសាធារណៈ ក៏ប៉ុន្តែជំងឺខ្លះ ដូចជា ជំងឺដង្កូវព្រូន តូចៗដែលសំងំនៅត្រាំត្រែង (អង់ដេមិក) នៅប្រទេសកម្ពុជាជាយូរយារណាស់មកហើយនោះ មិនសូវ មានរោគសញ្ញាដែលសហគមន៍ជាតិ យើងអាចស្គាល់អត្តសញ្ញាណជាទូលំទូលាយដោយងាយបានទេ ទោះបី ជំងឺទាំងនោះនៅតែជាបញ្ហាសុខភាពសាធារណៈ អាចនាំឱយប៉ះពាល់ដល់ស្ថានភាពប្រជានជន ជាពិសេស ស្ថានភាពអាហារូបត្ថម្ភ ដែលអាចមានផលប៉ះពាល់ជាអវិជ្ជមានដល់សុខភាពមាតា និងកុមារក៏ដោយ ។ រាជរដ្ឋាភិបាលជានិច្ចកាល បានឧបត្ថម្ភ គាំទ្រដល់សកម្មភាពប្រយុទ្ធ ឬលុបបំបាត់ជំងឺទាំងនេះ តាមរយៈកម្មវិធី ជាតិចំនួន៣គឺៈ ជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម និងជំងឺដង្កូវព្រូន ក្នុងនោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្តួចផ្តើមដោយផ្ទាល់ឱ្យក្រសួងសុខាភិបាល រៀបចំ

និងដាក់ឱ្យដំណើរការផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់ឆ្នាំ ២០១១-២០២ ហើយផែនការនេះ ទើបនឹងត្រូវបានកត់សំគាល់ក្នុង ***"សេចក្តីប្រកាសនៃ កិច្ចប្រជុំកំពូលអាស៊ីបូពាលើកទី៧ ស្តីពីការឆ្លើយតប ថ្នាក់តំបន់ទៅនឹងការគ្រប់គ្រងជំងឺគ្រុនចាញ់ និងការដោះស្រាយភាពស៊ាំនឹង ឱសថរបស់ ជំងឺគ្រុនចាញ់"*** ដែលត្រូវបានអនុម័តដោយប្រមុខរដ្ឋាភិបាលនានា ក្នុងកិច្ចប្រជុំអាស៊ីបូពា កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១២ នៅរាជធានីភ្នំពេញ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរ ចំពោះបុគ្គលិកនៃមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ បុគ្គលិកកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់-គ្រុនឈាម និងដង្កូវព្រូន តាមបណ្តាខេត្តនានា និងអង្គការជាដៃគូទាំងអស់ ដែលបានជួយគាំទ្រកម្មវិធីជាតិ ទាំង៣ លើផ្នែកបច្ចេកទេស និងថវិកាក្នុងការព្យាបាល-ការការពារ ការអប់រំសុខភាព និងការតាមដាន ស្រាវជ្រាវ វាយតំលៃ។ ជាមួយគ្នានេះ ខ្ញុំក៏សូមអរគុណ និងវាយតម្លៃខ្ពស់ចំពោះស្ថាប័នពាក់ព័ន្ធ រដ្ឋបាល មូលដ្ឋាន និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងសហការគ្នាគាំទ្រ កម្មវិធីជាតិទាំង៣នេះ រហូតទទួលបានជោគជ័យក្នុងការកាត់បន្ថយអត្រាឈឺ និងស្លាប់ ដោយជំងឺ គ្រុនចាញ់ ជំងឺគ្រុនឈាម ជំងឺស៊ីស្តូ ជំងឺដង្កូវព្រូន នៅតាមបណ្តាខេត្តនៃប្រទេសកម្ពុជា។

***ដើម្បីរួមចំណែកក្នុងអង្គសន្និបាតនេះ ខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនដូចតទៅៈ***

**ទី១**-ទោះបីកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បានរួមចំណែកដល់រាជរដ្ឋាភិបាលក្នុងការសំរេចសូចនាករ ស្ទួលរបស់គោលដៅអភិវឌ្ឍន៏សហស្សវត្សឆ្នាំ២០១៥ បានក្នុង ៣-៤ឆ្នាំមុនកាលកំណត់ក្នុងនោះ មាន ការកាត់បន្ថយអត្រាស្លាប់ដោយគ្រុនចាញ់ បានយ៉ាងច្រើនក្នុងពេលថ្មីៗនេះក៏ដោយ យើងនៅមានផែនទី ផ្លូវដ៏វែង ដែលយើងត្រូវបន្តដើរតទៅទៀតក្នុងការអនុវឌ្ឍន៏ផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់ ឆ្នាំ២០១១-២០២៥ ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រ កម្ពុជាទើបនឹងបានចុះហត្ថលេខាគាំទ្រកាលពីដើមឆ្នាំ២០១១ថ្មីៗ។ ដើម្បីប្រែក្លាយ យុទ្ធសាស្ត្រជាតិ នេះឱ្យក្លាយជា សកម្មភាពពិតៗជាក់ស្តែងត្រូវមានការកំណត់ឱ្យច្បាស់លាស់នូវក្របខ័ណ្ឌ

ការងារជាក់លាក់តាមដំណាក់កាលនីមួយៗ (Framework for Implementation for each Phase) ដើម្បីងាយស្រួល ប្រតិបត្តិតាមដំណាក់ទាំងបីគឺ ឆ្នាំ២០១១-២០១៥ ឆ្នាំ២០១៦-២០២០ និង២០២១-២០២៥ ហើយត្រូវធ្វើ បច្ចុប្បន្នភាព ក្របខណ្ឌ័ការងារនេះឱ្យបានទៀងទាត់ដើម្បីឆ្លើយតបទៅនឹង សភាពការណ៏ជាក់ស្តែង របស់ សម័យកាល និងទីកន្លែងនីមួយៗក្នុងនោះ រួមមាន ធ្វើបច្ចុប្បន្នភាពតម្រូវ ការធនធានផង។

**ទី២**-ចំពោះការអនុវឌ្ឍន៍ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនដើម្បីលុបបំបាត់ជំងឺគ្រុនចាញ់ នៅមូលដ្ឋាន ខ្ញុំសូមអំពាវនាវដល់ក្រុមការងារពិសេសលុបបំបាត់គ្រុនចាញ់តាមខេត្តនីមួយៗ ដែលមាន អភិបាលរងខេត្តមួយរូបជាប្រធាន សូមមេត្តាជួយសំរួលទំនាក់ទំនងជាមួយម្ចាស់ការដ្ឋានកសិកម្ម-ឧហ្សាហកម្ម-រ៉ែ និងគមនាគមន៍ដើម្បី ធ្វើយ៉ាងណាឱ្យពលករទាំងអស់ជា ពិសេសពលករចល័តបាន ទទួលព័ត៌មាន ត្រឹមត្រូវ ស្តីពីជំងឺគ្រុនចាញ់ ក៏ដូចបានទទួលសេវាមានគុណភាពក្នុងការធ្វើរោគវិនិច្ឆ័យ-ព្យាបាលជំងឺនេះ ឱ្យបានទាន់ពេល វេលាដោយ មិនចាំបាច់ឱ្យពួកគាត់បង់ថ្លៃសេវា។ ទន្ទឹមនោះ ត្រូវបន្ត ពង្រីកសហការជាមួយសេវាវេជ្ជសាស្ត្រ-ឱសថសាស្ត្រ ឯកជន ក្នុងការពិនិត្យព្យាបាលជំងឺគ្រុនចាញ់ និង ជាមួយអ្នកលក់មុង ដើម្បីបង្កើនអត្រា ប្រើប្រាស់មុង ជ្រលក់ថ្នាំឱ្យកាន់តែទូលំទូលាយ។

**ទី៣**-ត្រូវយកចិត្តដាក់ដល់ការតាមដានអនុវត្តន៍សេចក្តីប្រកាស នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី៧ ស្តីពីការឆ្លើយតប ថ្នាក់តំបន់ ទៅនឹងការគ្រប់គ្រងជំងឺគ្រុនចាញ់ និងការដោះស្រាយភាពស៊ាំនឹងឱសថរបស់ជំងឺគ្រុនចាញ់ដោយ ធ្វើអន្តរាគមន៍ពហុវិស័យទាំងក្នុងប្រទេស ទាំងក្នុងតំបន់ ជាពិសេសតំបន់អាស៊ាន និងអនុតំបន់មេគង្គ ក្នុងនោះត្រូវពង្រីកសហប្រតិបត្តិការឆ្លងដែនជាមួយប្រទេសថៃ-ឡាវ និងវៀតណាមតាមយន្តការថ្នាក់កណ្តាល-ខេត្ត-ក្រុង ស្រុក និងមូលដ្ឋាន។

**ទី៤**-ក្រសួងសុខាភិបាលបានចេញសេចក្តីប្រកាសពតិមានចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០០៩ ក្នុងចំណោម ហាមឃាត់ការនាំចូល-ផលិត-ចរាចរ ឱសថគ្រុនចាញ់ដែលផ្អែកលើអារតេមិស៊ីនីនតែមួយមុខ។ អស់រយៈកាល ២ឆ្នាំកន្លងមកនេះ និង នៅអនាគតមានតែ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ ទេ ដែលក្រសួងអនុញ្ញាតឱ្យចុះបញ្ជីកាឱសថព្យាបាលគ្រុនចាញ់ ហេតុនេះ សូមអង្គភាពពាក់ព័ន្ធ ជាពិសេសនាយកដ្ឋានឱសថ ចំណីអហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង គ្រប់គ្រង តាមដានចរាចរឱសថគ្រុនចាញ់ នៅក្នុងទីផ្សារឱ្យមានប្រសិទ្ធភាពដោយសហការយ៉ាងជិតស្និទ្ធជាមួយ មជ្ឈមណ្ឌលជាតិ និងអង្គភាពពាក់ព័ន្ធនានា ដូចជា រដ្ឋបាលមូលដ្ឋាន និងអង្គភាពនគរបាលជាដើម។

**ទី៥**-ចំពោះជំងឺគ្រុនឈាមទោះ បីជាធម្មតាអង្គការសុខភាពពិភពលោកកត់សំគាល់ថា ការផ្ទុះរាត្បាត ជំងឺនេះតែងកើនមានក្នុងប្រទេសនីមួយៗក្នុង៣-៥ឆ្នាំក៏ដោយ ក៏ក្នុងឆ្នាំ២០១៣-២០១៤ ដែលជាឆ្នាំ ទី១-ទី២ រាប់ពីឆ្នាំ២០១២ មក យើងត្រូវបន្តប្រុងប្រយ័ត្នជានិច្ច ក្នុងការរក្សាជីវិតកុមារ ព្រោះ កន្លងមក ទោះក្នុងឆ្នាំគ្មានការផ្ទុះរាតត្បាតក៏ដោយ ក៏នៅកម្ពុជា ជំងឺនេះតែងផ្តាច់ជីវិតកុមារ ២-៣នាក់ ជា មធ្យមក្នុង១សប្តាហ៍នៅរដូវវស្សា។ ជាឧទាហរណ៍ឆ្នាំ២០០៦ដែល មិនមែនជាឆ្នាំមានផ្ទុះ រាតត្បាត ក៏មានគ្រុនឈាមស្លាប់ជាង១០០នាក់ ដែរ។ ម្យ៉ាងទៀតឆ្នាំនេះតាមការផ្សព្វផ្សាយរបស់ក្រសួងធនធាន ទឹក ស្ថានភាពអាកាសធាតុមានភ្លៀងកក់ខែ និងមានសភាពខុសធម្មតាមួយចំនួនទៀត ហេតុនេះ សូមអង្គសន្និបាតពិភាក្សាស៊ីជំរៅអំពីការត្រៀមអន្តរាគមន៍។ ដោយឡែក

ចំពោះ ថ្នាំអាបែត សូមប្រធាន មន្ទីរសុខាភិបាល ចាត់វិធានការមកដឹកជញ្ជូន បានទាន់ពេល វេលាចាប់ពីចុងខែមេសាតទៅទោះបី ខេត្តមួយចំនួនមានអាបែតសល់ក្នុងស្តុកខ្លះៗក៏ដោយ។

**ទី៦** ~ចំពោះជំងឺដង្កូវព្រូនសូមធ្វើសកម្មភាពដោយផ្តល់អាទិភាពដល់ការរក្សាអត្រាគ្របដណ្តប់ការផ្តល់ថ្នាំ ទំលាក់ព្រូននៅតាមសាលារៀនឱ្យនៅខ្ពស់ជាង៩០% ហើយសូមការពង្រីកអត្រាគ្របដណ្តប់ សំរាប់ស្ត្រី ក្នុងវ័យបន្តពូជ ដើម្បីរួមចំណែកលើកកំពស់សុខភាពមាតា និងកុមារ។

ជាថ្មីម្តងទៀតខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះបណ្តាប្រទេសម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងស្ថានប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដែលបានខិតខំប្រឹងប្រែងផ្តល់ការគាំទ្រ ទាំងស្មារតី សំភារៈ និងថវិកាដល់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ រហូតទទួលបានលទ្ធផលល្អប្រសើរកន្លងមក។ ខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំផងដែរថា ម្ចាស់ជំនួយ និងដៃគូ ទាំងអស់នឹងនៅតែបន្តជួយដល់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ និងធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធថែមទៀត ដើម្បីរួមកាត់បន្ថយអត្រាឈឺ/ស្លាប់ ដោយសារជំងឺ គ្រុនចាញ់ គ្រុនឈាម ដង្កូវព្រូន និងជំងឺផ្សេងៗទៀតដែលចំលងដោយមូស។

ជាទីបញ្ចប់ ក្នុងនាមក្រសួងសុខាភិបាល និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមជូនពរបវរមហាប្រសើរចំពោះ គណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងសមាជិក សមាជិកានៃអង្គពិធី ទាំងមូល សូមប្រកបដោយពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**ខ្ញុំសូមប្រកាសបើក** សន្និបាតបូកសរុបលទ្ធផលការងារមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ ឆ្នាំ២០១២ ចាប់ពីពេលនេះតទៅ។ សូមអរគុណ